## Long Beach Unified School District

### សេចក្តីអនុញ្ញាត និង ការបញ្ចេញចុះផ្សាយអំពីសិស្ស

ខ្ញុំសូមផ្តល់សេចក្តីអនុញ្ញាតតាមរយៈនេះទៅកាន់ក្រសួងអប់រំ ឪស្រ្ទីត ឡុងប៊ីច អាជ្ញាធរ បុគ្គលិក ភ្នាក់ងារ និង អ្នកផ្តល់ជំនួយផ្សេងៗ ដែលប្រើឈ្មោះហៅរួមតែមួយ គឺ LBUSD សំរាប់ ... ប្រើការទូទៅ ប្រើជាផ្លូវចំណេញ ប្រើបត់បែន ធ្វើការកែប្រែ ផលិតឡើងវិញ ប្រើបន្ថែមបន្ថយ ចែករាយផ្សាយ និង តាំងបង្ហាញជាសាធារណៈ ដែលកំពុងប្រើបាននៅពេលឥឡូវ ឬ កែប្រែប្រើសំរាប់នៅពេលលើកក្រោយ អំពីរូបភាពនៃសិស្សរបស់ខ្ញុំ ឬ ភាពស្រដៀងនៃសិស្សរបស់ខ្ញុំ ដែលមានទាំងឈ្មោះ និង ឬ សម្លេង រួមទាំងការសរសេរ និង រូបគំនូរ ដែលជាស្នាដៃនៃសិស្សរបស់ខ្ញុំ តាមការផ្សព្វផ្សាយគ្រប់កន្លែង ដោយរៀបដាក់បញ្ចូលរួមគ្នា ឬ សំរាប់ការចុះផ្សាយនៅក្នុង កាត់កាឡុក កូនសៀវភៅ សៀវភៅ ទស្សនាវដ្តី ការតាំងបង្ហាញរូបថត រូបភាពយន្ត វិឌីអូ គេហទំព័រ និង ឬ ការចុះផ្សាយពាណិជ្ជកម្ម ជារបៀបផ្តល់ព័ត៌មានទូទៅ ជារបៀបកម្មវិធីសិក្សា កម្មវិធីហ្វឹកហ្វឺន ការរាយផ្សាយជូនសធារណជន ការទាក់ទាញចំណែកពីបុគ្គល ឬ ការរាយផ្សាយកម្មវិធី ដែលទាក់ទងការប្រើមធ្យោបាយសព្វយ៉ាង ដែលក្រសួងអប់រំ LBUSD ចាត់ទុកជាអំពើត្រឹមត្រូវ ស្ថិតក្រោមការយកចិត្តទុកដាក់របស់គេតែមួយគត់ ហើយគេអាចប្រើ ឬ មិនប្រើក៏បានអំពីឈ្មោះរបស់ខ្ញុំ ឬ ឈ្មោះនៃសិស្សរបស់ខ្ញុំ ឬ ប្រើជាឈ្មោះក្លែងក្លាយ ដែលអាចមានជាព័ត៌មានពិត ឬ ជាភាពក្លែងក្លាយអំពីជីវប្រវត្តិ ។ ឳកាសសំរាប់ធ្វើការចុះផ្សាយ គឺល្អ និង មានប្រយោជន៍ ដែលសមស្របតាមការចុះហត្ថលេខារបស់ខ្ញុំនៅផ្នែកខាងក្រោម ។

ខ្ញុំសូមផ្តល់សេចក្តីអនុញ្ញាតនៃសិទ្ធិនេះ ដោយទទួលស្គាល់ថា នឹងគ្មានសគុណអ្វីទេសំរាប់ផ្តល់សងមកកាន់ខ្ញុំ ឬ សិស្សរបស់ខ្ញុំ ។ ខ្ញុំយល់ព្រម និង ទទួលស្គាល់ថា សិទ្ធិ និង ផលប្រយោជន៍ទាំងអស់ រួមទាំងការគូពីចម្លងផងនៅលើកិច្ចការទាំងប៉ុន្មាន ដែលបានបង្កើតដោយក្រសួងអប់រំ LBUSD និង មានការទាក់ទងមកលើការយល់ព្រមនេះ គឺជាកម្មសិទ្ធតែមួយគត់របស់ក្រសួងអប់រំ LBUSD ហើយខ្ញុំគ្មានសិទ្ធិអ្វីសំរាប់ការទាមទារ ។ ខ្ញុំក៏ទទួលស្គាល់ដែរថា ក្រសួងអប់រំ LBUSD គ្មានទទួលការចែងតំរូវអ្វីទាល់តែសោះសំរាប់ការប្រើឈ្មោះនៃសិស្សរបស់ខ្ញុំ និង រូបថត ភាពស្រដៀង សម្លេង ហត្ថលេខា អក្សរដៃ ឬ រូបគំនូររបស់គេតាមវិធីពិសេសណាមួយ ។

ខ្ញុំសូមបោះបង់ចោលសិទ្ធិតាមរយៈនេះ ដោយទទួលយល់ព្រមថា ខ្ញុំ ឬ សិស្សរបស់ខ្ញុំ នឹងមិនអាចសុំពិនិត្យ ឬ ទទួលស្គាល់ជាមុនសិនបានទេអំពីការចុះផ្សាយរូបថតណាមួយ ភាពស្រដៀង រូបនៅក្នុង វិឌីអូ សម្លេងថត ឬ កិច្ចការផ្សេងៗ ដែលប៉ះពាល់មកលើការប្រគល់ សេចក្តីអនុញ្ញាត និង ការបញ្ចេញចុះផ្សាយអំពីសិស្ស នេះ ។ ខ្ញុំយល់ថា ស្ថិតក្រោមច្បាប់នៃរដ្ឋ កាលីហ្វ័រញ៉ា បុគ្គលណាក៏ដោយ ក៏មានសិទ្ធិពេញលេញសំរាប់គ្រប់គ្រងមកលើការប្រើឈ្មោះរបស់ខ្លួន រួមទាំងភាពស្រដៀង និង រូបថតរបស់គេផង ហើយតាមរយៈនេះ គឺខ្ញុំសូមផ្តល់សិទ្ធិទាំងអស់ និង យល់ស្របតាមទាំងស្រុងទៅកាន់ក្រសួងអប់រំ LBUSD ភ្នាក់ងារ និង អ្នកទទួលបន្ទុករបស់គេ ដោយមិនធ្វើការប្តឹង ឬ ប្រើអំពើប្រឆាំងជាមួយក្រុមណាមួយឡើយចំពោះការទទួលខុសត្រូវទាំងអស់ ទោះជាកំពុងដឹងនៅពេលឥឡូវនេះក្តី ឬ កើតឡើងនៅពេលជាបន្តទៅក្តី ដោយមូលហេតុពីទំនាក់ទំនងនៃការប្រើសិទ្ធិពីក្រុមណាមួយមកលើសេចក្តីអនុញ្ញាតនេះ ។

ខ្ញុំបានអានអំពីសេចក្តីយល់ព្រមនៅផ្នែកខាងលើ និង យល់ស្របយ៉ាងពេញលេញអំពីការរៀបរាប់តាមលក្ខណៈរបស់វា ។ ខ្ញុំជាអ្នកតំណាងសំរាប់ខ្លួនខ្ញុំ និង ទទួលអះអាងថា ខ្ញុំមានអាយុយ៉ាងតិច 18 ឆ្នាំ ហើយខ្ញុំមានសិទ្ធិសំរាប់ចុះកុងត្រាមកលើឈ្មោះនៃសិស្សរបស់ខ្ញុំ ហើយខ្លួនខ្ញុំក្តី ឬ សិស្សរបស់ខ្ញុំក្តី គឺគ្មានបញ្ហាជាប់ទាក់ទងអ្វីទេពីពេលមុនមក ដែលអាចឃាត់ឃាំង ឬ ដាក់កំរិតមកលើខ្លួនខ្ញុំអំពីការចុះហត្ថលេខាជាមួយការប្រគល់ សេចក្តីអនុញ្ញាត និង ការបញ្ចេញចុះផ្សាយអំពីសិស្ស នេះ ។

សេចក្តីអនុញ្ញាត និង ការបញ្ចេញចុះផ្សាយអំពីសិស្ស នេះ នឹងទទួលការគ្រប់គ្រងដោយច្បាប់នៃរដ្ឋ កាលីហ្វ័រញ៉ា និង អាចប្រើជាផ្លូវការត្រឹមត្រូវបាន រួមទាំងបង្ហាញការយល់ព្រមទាំងស្រុងផងរវាងក្រសួងអប់រំ LBUSD និង ខ្លួនខ្ញុំផ្ទាល់ ដែលទាក់ទងមកលើកិច្ចការនេះ ។

ខ្ញុំសូមអះអាងថា ខ្ញុំជាអ្នកគ្រប់គ្រងពេញច្បាប់នៃសិស្សក្រោមអាយុមិនទាន់ជាមនុស្សធំ ដែលបានជាប់រូបនៅក្នុងរូបថត ឬ មានជាប់ភាពស្រដៀងនៃរូបរបស់ខ្លួននៅក្នុងរូបថត ដែលនឹងយកទៅប្រើការទូទៅ ឬ ការចុះផ្សាយផ្សេងៗដូចបានបង្កើតដោយក្រសួងអប់រំ LBUSD និង ស្របតាមអ្វីដូចបានរៀបរាប់នៅផ្នែកខាងលើ ។

ខ្ញុំសូមផ្តល់សេចក្តីអនុញ្ញាតបន្ថែម និង ទទួលស្របតាមអ្វីដូចបានរៀបរាប់នៅផ្នែកខាងលើ:

______________________________ __________ ____________________ ______________
ហត្ថលេខានៃមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស ថ្ងៃខែ ហត្ថលេខានៃសិស្ស ថ្ងៃខែ

______________________________ __________ ____________________
ឈ្មោះនៃសិស្ស (សរសេរអក្សរច្បាស់)

ហត្ថលេខានៃមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស ថ្ងៃខែ

____________________
សាលារៀន

______________________________
លេខទូរស័ព្ទ

បើមានអាយុលើស 18 ឆ្នាំ និង ក្នុងឋានៈជាសិស្ស ចូរចុះហត្ថលេខានៅតាមបន្ទាត់នេះ ____________________ ______________
ហត្ថលេខានៃសិស្ស ថ្ងៃខែ

__________________________ ____________________
ឈ្មោះនៃសិស្ស (សរសេរអក្សរច្បាស់) លេខទូរស័ព្ទ